# ការណែនាំអំពីការសម្លាប់មេរោគ សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន

## ការសម្លាប់មេរោគ សម្រាប់អាងត្រាំជើងដែលអាចប្តូរទឹកបាន

អាងត្រាំជើងប្រភេទដែលមានប្រព័ន្ធប្តូរទឹក គឺដំណើរការដោយបូមទឹកចេញពីអាង រួចបញ្ជូនត្រឡប់ចូលទៅក្នុងអាងវិញ តាមរយៈបំពង់។ សូមអនុវត្តតាមការណែនាំរបស់អ្នកផលិតជានិច្ច អំពីវិធីសម្អាត និងសម្លាប់មេរោគនៅក្នុងអាងត្រាំជើង។

| នីតិវិធីនៃការសម្អាត និងការសម្លាប់មេរោគ | |
|---|---|
| **ជំហានទី ១** | **សម្អាត** អាងជាមួយសាប៊ូ និងទឹក។ ប្រើច្រាសដើម្បីដុសវា។ |
| **ជំហានទី ២** | **ចាក់ទឹកចូល** ក្នុងអាង គឺទឹកសាប៊ូ និងក្តៅឧណ្ឌៗ ត្រឹមគំនូស។ បើកប្រព័ន្ធចរាចរទឹករយៈពេលជាង ៥ នាទី។ បង្ហូរទឹកចេញ រួចលាងសម្អាតនឹងទឹកស្អាត។ ដំណើរការប្រព័ន្ធចរាចរទឹកម្តងទៀត ដោយប្រើទឹកស្អាត រហូតទាល់តែអស់ជាតិសាប៊ូ។ |
| **ជំហានទី ៣** | **សម្លាប់មេរោគ** ដោយប្រើ[សារធាតុសម្លាប់មេរោគកម្រិតមធ្យម]* សូមអនុវត្តតាមការណែនាំរបស់អ្នកផលិត សម្រាប់ការប្រើប្រាស់ឱ្យបានត្រឹមត្រូវ។ ចាក់ទឹកចូលក្នុងអាងឱ្យកម្រិតទឹកនៅខ្ពស់ជាងក្បាលបាញ់ទឹក (jets) ហើយបើកដំណើរការប្រព័ន្ធចរន្តទឹក ក្នុងរយៈពេលដែលបានកំណត់ ដើម្បីឱ្យសារធាតុសម្លាប់មេរោគមានប្រសិទ្ធភាព។ |
| **ជំហានទី ៤** | **បង្ហូរទឹក** ចេញពីអាង។ |
| **ជំហានទី ៥** | **ចាក់ទឹកចូល** ក្នុងអាងគឺទឹកក្តៅឧណ្ឌៗ នៅនៅត្រឹមលើក្បាលបាញ់ទឹក (jets) និងដំណើរការប្រព័ន្ធចរាចរទឹក ដើម្បីលាងសម្អាតសារធាតុសម្លាប់មេរោគ តាមការណែនាំរបស់រោងចក្រ។ |
| **ជំហានទី ៦** | **បង្ហូរទឹក** ចេញពីអាង។ យកកន្សែងពោះគោជូតវាឲ្យស្ងួត។ |

### កំណត់សម្គាល់បន្ថែម

- ☑ ដោះ សម្អាត និងសម្លាប់មេរោគលើតម្រង ឬ screens រាល់ថ្ងៃ។
- ☑ សម្អាត និងត្រាំជក់ដុស (ដែលបានប្រើក្នុងជំហានទី ១) ក្នុងទឹកថ្នាំសម្លាប់មេរោគជារៀងរាល់ថ្ងៃ រួចទុកឱ្យវាស្ងួត។
- ☑ សូមអនុវត្តតាមការណែនាំរបស់អ្នកផលិតសម្រាប់ឧបករណ៍ និងសារធាតុសម្លាប់មេរោគទាំងអស់។
- ☑ សូមប្រើតែថ្នាំសម្លាប់មេរោគដែលត្រូវបានអនុម័តដោយសុខាភិបាលកាណាដាប៉ុណ្ណោះ។ ទឹកថ្នាំសម្អាតប្រភេទអូសាវែលសម្រាប់ប្រើក្នុងផ្ទះក៏អាចប្រើបានដែរ។

* *សារធាតុលាងសម្អាតប្រភេទអូសាវែល កំហាប់ 5000ppm អាចប្រើរយៈពេលដំណើរការ ១០ នាទី ដើម្បីសម្លាប់មេរោគក្នុងអាង តាមជំហានខាងលើ។*

simcoe muskoka DISTRICT HEALTH UNIT

**Tel:** 705-721-7520
**Toll free:** 1-877-721-7520
**www.smdhu.org**